Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលសង្កេតនៃការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ឆ្នាំ២០២២

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល បានសង្កេតលើដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងសិក្សាលើបញ្ជីឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៦ ដល់បច្ចុប្បន្ននេះ។ ការឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែល បានដាក់ពង្រាយអ្នកសង្កេតការណ៍ជាលេខាខេត្តរបស់ខ្លួន សង្កេតមើលតាមការិយាល័យចុះឈ្មោះ ចំនួន ៩២ឃុំសង្កាត់ ក្នុង ២៣ខេត្ត។ រីឯការធ្វើសវនៈកម្មបញ្ជីឈ្មោះបោះឆ្នោត គឺជាការសិក្សាលើគុណភាពបញ្ជីឈ្មោះបោះឆ្នោតបឋមឆ្នាំ២០២២នេះ ដើម្បីពិនិត្យមើលករណីដូចជា ការផ្ទៀងផ្ទាត់វត្តមាននៅកន្លែងរស់នៅជាមួយបញ្ជីឈ្មោះបោះឆ្នោត ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតស្ទួនក្នុងបញ្ជី ភាពត្រឹមត្រូវនៃព័ត៌មានក្នុងបញ្ជីឈ្មោះបោះឆ្នោត រួមទាំងការប្រើប្រាស់ឯកសារលើបញ្ជីឈ្មោះបោះឆ្នោត និងបញ្ហាប្រឈមផ្សេងៗ នៃអ្នកមានសិទ្ធិបោះឆ្នោត ពេលអំឡុងពេលទៅចុះឈ្មោះបោះឆ្នោត។

យោងតាមលទ្ធផលរកឃើញ ទាក់ទងនឹងចំណុចទាំងឡាយនៃបញ្ជីឈ្មោះបោះឆ្នោត ដែលបានសិក្សា និងសង្កេត ខុមហ្វ្រែលយល់ឃើញថា បញ្ជីឈ្មោះបោះឆ្នោតនៅតែមានគុណភាពអាចទទួលយកបាន លើកលែងតែសិទ្ធិចុះឈ្មោះ សិទ្ធិបោះឆ្នោត និងការចេញឯកសារបញ្ជាក់ការចុះឈ្មោះបោះឆ្នោតខ្លះ នៅតែជាបញ្ហាប្រឈម និងមិនទាន់ដោះស្រាយបាននៅឡើយ ។ ការណ៍នេះ តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ពីស្ថាប័ន គ.ជ.ប និងរដ្ឋាភិបាល រួមទាំងស្ថាប័នរដ្ឋសភា ដែលត្រូវបើកផ្លូវផ្នែកច្បាប់ឱ្យមានការចុះឈ្មោះប្រជាពលរដ្ឋរស់នៅក្រៅប្រទេស មានសិទ្ធិចុះឈ្មោះនៅក្រៅប្រទេសបាន ។

លទ្ធផលសង្កេតដំណើរការចុះឈ្មោះ និងសិក្សាបញ្ជីឈ្មោះបោះឆ្នោត សង្ខេបការរកឃើញដូចខាងក្រោម ៖

## ១. លទ្ធផលនៃការចុះឈ្មោះបោះឆ្នោត

តាមតួលេខនៃស្ថិតិប៉ាន់ប្រមាណរបស់ គ.ជ.ប បើប្រៀបធៀបជាមួយឆ្នាំកន្លងមក ខុមហ្វ្រែលសង្កេតឃើញថា គ.ជ.ប បានទម្លាក់តួលេខប៉ាន់ស្មានខ្លាំង ។ ទម្លាក់តួលេខប៉ាន់ស្មាននេះ ខុមហ្វ្រែលមិនឃើញមានហេតុផលណាមួយជាក់លាក់ ដែលជាមូលដ្ឋានអំណះអំណាងនោះទេ ។ ស្ថិតិប៉ាន់ស្មានរបស់ គ.ជ.ប ចំពោះអ្នកមានសិទ្ធិបោះឆ្នោតគ្រប់អាយុ ១៨ឆ្នាំឡើង មានចំនួន ១០,៨៧៧,០១៧នាក់ ការិយាល័យបោះឆ្នោតប៉ាន់ស្មានចំនួន ២៣,៧៦០ការិយាល័យ និងស្ថិតិប៉ាន់ស្មានអ្នកចុះឈ្មោះថ្មី ចំនួន ៤០៩,០៥៦នាក់ ។ លទ្ធផលនៃការចុះឈ្មោះ មានឈ្មោះអ្នកបោះឆ្នោតក្នុង

បញ្ជីឈ្មោះឆ្នាំ២០២២ មានចំនួន ៩,៧១០,៦៤៥នាក់ ស្មើនឹង ៨៩.២៨ភាគរយ ធៀបនឹងចំនួនប៉ាន់ស្មានអ្នកគ្រប់អាយុ ១៨ឆ្នាំឡើង ។

**២. សង្កេតដំណើរការចុះឈ្មោះបោះឆ្នោត និងទិដ្ឋភាពនៃទីតាំងចុះឈ្មោះ**

**ទីតាំងចុះឈ្មោះ និងការបិទបញ្ជីឈ្មោះចុងក្រោយ៖** ខុមហ្វ្រែល សង្កេតឃើញថា ក្នុងចំណោមឃុំសង្កាត់បានសង្កេត គឺក្រុមចុះឈ្មោះបោះឆ្នោត នៅតែបន្តការចុះឈ្មោះដល់អ្នកគ្រប់អាយុបោះឆ្នោតដល់ទីតាំងភូមិមួយចំនួន ទោះមិនគ្រប់ភូមិក៏ដោយ។ កាលវិភាគសម្រាប់ក្រុមចុះឈ្មោះបោះឆ្នោតនៅគ្រប់ទីតាំងមើលឃើញថា បានបិទយ៉ាងត្រឹមត្រូវសម្រាប់ប្រជាពលរដ្ឋទៅពិនិត្យ (ខុមហ្វ្រែលសង្កេត ៩២ឃុំសង្កាត់ ក្នុង ២៣រាជធានី ខេត្ត) ។

**ការរៀបចំបិទបញ្ជីឈ្មោះ** ៖ រីឯការបិទផ្សាយបញ្ជីឈ្មោះចុងក្រោយនៅកន្លែងទីតាំងចុះឈ្មោះ មិនមានព័ត៌មានថា ការបិទបញ្ជីឈ្មោះ មិនបង្កឱ្យមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋធម្មតាក្នុងការមើលនោះទេ ។ ទោះជាយ៉ាងណា ការបិទនេះ វាបានប៉ះពាល់ដល់ជនពិការដែលអង្គុយលើរទេះរុញនៅកន្លែងខ្លះផងដែរ ព្រោះថា ទីកន្លែងបិទបញ្ជីនោះមិនមានទីជម្រាលសម្រាប់ជនពិការឡើង និងកន្លែងខ្លះមានកម្ពស់លើសពី ១,៥ម៉ែត្រថែមទៀត ។

**ទិដ្ឋភាពទូទៅនៅកន្លែងចុះឈ្មោះ** ៖ តាមរយៈនៃការចុះសង្កេតក្រុមចុះឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់ទាំង៩២ បានបង្ហាញឱ្យឃើញថា ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ បានសង្កេតឃើញនូវករណីចំនួន ៣ ដែលបានកត់សម្គាល់ឃើញ រួមមាន ១) ការខូចខាតសម្ភារៈនៅកន្លែងចុះឈ្មោះខ្លះ ដូចជា ខូចកាមេរាថតរូប ឌុយសាកភ្លើង ឧបករណ៍ផ្ទុកថាមពល (Power Bank) និងកុំព្យូទ័របើកមិនចេញ ។ ២) កន្លែងខ្លះ មិនឃើញវត្តមានក្រុមប្រឹក្សាឃុំសង្កាត់ប្រចាំការនៅតាមភូមិខណៈក្រុមចុះឈ្មោះបានចល័ត ។ ៣) មានសមាជិកក្រុមប្រឹក្សាឃុំសង្កាត់កន្លែងខ្លះ ភ្នាក់ងារគណបក្ស អ្នកសង្កេតការណ៍សមាគម បានអង្គុយស្រង់ឈ្មោះប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោត ព្រមទាំងថតអត្តសញ្ញាណប័ណ្ណយកថែមទៀត (កន្លែងខ្លះ) ។ ៤) អ្នកសង្កេតការណ៍មកពីសមាគមខ្លះ បានជួយសម្រួលក្នុងការយកឯកសារអ្នកមកចុះឈ្មោះទៅឱ្យចៅសង្កាត់វាយត្រាបញ្ជាក់ក្នុងការប្រើប្រាស់ក្នុងដំណាក់ការចុះឈ្មោះ ។ ៥) សាលាឃុំខ្លះ ក្នុងដំណាក់កាលចុះឈ្មោះនៅសាលាឃុំ សង្កេតឃើញថា បានបើកទ្វារសាលាឃុំចោល ប៉ុន្តែពុំមានអ្នកមកធ្វើការនោះទេ ហើយក៏គ្មានការបិទស្លាកជូនដំណឹងស្តីពីដំណើរការចុះឈ្មោះបោះឆ្នោតនោះដែរ ។ ទាំងនេះ គ្រាន់តែជាការសង្កេតឃើញ ខុមហ្វ្រែលនឹងមិនវាយតម្លៃថា ករណីទាំងនេះ វាប៉ះពាល់កម្រិតប៉ុណ្ណាសម្រាប់ការចុះឈ្មោះបោះឆ្នោតនោះទេ ។

**ការផ្តល់ព័ត៌មានពីដំណើរការចុះឈ្មោះបោះឆ្នោត៖** លទ្ធផលនៃការសង្កេតនៅទីតាំងទាំង ៩២ឃុំសង្កាត់ និង ២៨៩ លើក មានទីតាំងចំនួន ២៤៥កន្លែង ស្មើនឹង ៨៤.៧៨ភាគរយ ប្រជាពលរដ្ឋបង្ហាញថា ខ្លួនគាត់បានដឹងពីព័ត៌មាននៃការចុះឈ្មោះបោះឆ្នោតពីមុនមក ។ ២៣កន្លែង/លើក ស្មើនឹង ៧.៩៦ភាគរយ ទើបតែដឹងពេលក្រុមចុះឈ្មោះមានវត្តមាន ។ ទាក់ទងជាមួយការសម្ភាសន៍ប្រជាពលរដ្ឋនៅកន្លែងចុះឈ្មោះបោះឆ្នោត ចំនួន ២៨៩នាក់ ស្តីពីព័ត៌មានអត្តសញ្ញាណប័ណ្ណប្រភេទ១ និង ប្រភេទ២ អស់សុពលភាព ដែលបានប្រកាសដោយ គ.ជ.ប ថាមិនអាចប្រើប្រាស់សម្រាប់ចុះឈ្មោះ ឬបោះឆ្នោតបាននោះ ជាលទ្ធផលបានបង្ហាញថា ១២១រូប ស្មើនឹង ៤១.៨៧ភាគរយ នៃអ្នកឆ្លើយតបមិនធ្លាប់បានទទួលព័ត៌មានពីអត្តសញ្ញាណប័ណ្ណអស់សុពលភាពនេះពីមុនមកនោះទេ ។ ប្រជាពលរដ្ឋមួយចំនួនបានធ្វើការចំណាកស្រុកទៅក្រៅកន្លែងរស់នៅ ករណីនេះ អ្នកឆ្លើយតបចំនួន ១២៥នាក់ស្មើនឹង ៤៨.៤៥ភាគរយ ឆ្លើយថាពួកគេ មិនបានដឹងអ្វីទាំងអស់ពីរបៀបដោះស្រាយឱ្យអ្នកទាំងនោះបានដឹង ។

**សកម្មភាពសមាគម និងអង្គការសង្គមស៊ីវិល** ៖ ក្នុងអំឡុងពេលដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលមានវត្តមានចំនួន ២៩៨លើក ក្នុងឃុំសង្កាត់ចំនួន ៩២ ក្នុង ២៣ខេត្ត បានសង្កេតឃើញថា ៥៨លើក ស្មើនឹង ១៩.៨ភាគរយនៃចំនួនចុះសង្កេតការណ៍ ការចុះឈ្មោះបោះឆ្នោតសរុប ឃើញមានវត្តមានអ្នកសង្កេតការណ៍មកពីសមាគម អង្គការមិនមែនរដ្ឋាភិ

បាល ។ ទោះបី គ.ជ.ប សម្រេចចុះបញ្ជីឈ្មោះអ្នកសង្កេតការណ៍ពីសមាគម និងអង្គការសង្គមស៊ីវិល មានចំនួន ៨ស្ថាប័នក៏ដោយ ។

**ភ្នាក់ងារគណបក្សនយោបាយ** ៖ ភ្នាក់ងារគណបក្សនយោបាយច្រើនជាងគេដែលបានចូលរួមសង្កេតក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតគឺ គណបក្សប្រជាជនកម្ពុជា។ ជាក់ស្តែងនៅទីតាំងគោលដៅដែលខុមហ្វ្រែលបានសង្កេត ចំនួន ២៩៨លើកមាន ២២៦លើក ស្មើនឹង ៧៦.៣៥ភាគរយ ឃើញមានវត្តមានភ្នាក់ងារគណបក្ស ។

**ការប្រតិបត្តិរបស់ក្រុមចុះឈ្មោះបោះឆ្នោត** ៖ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានសង្កេតឃើញថា ក្រុមចុះឈ្មោះបោះឆ្នោតបានជួបនូវបញ្ហាចំនួន ៣៥លើកស្មើនឹង ១២ភាគរយនៃការសង្កេតសរុប បានឃើញក្រុមចុះឈ្មោះ ជួបបញ្ហាក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត រួមមាន អវត្តមានរបស់មន្ត្រីចុះឈ្មោះបោះឆ្នោត កន្លែងខ្លះមានឧបករណ៍រអាក់រអួលមិនដំណើរការ ។

**៣. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត**

**ឈ្មោះដូចគ្នា/ស្ទួនធៀប ៤លក្ខខណ្ឌ ក្នុងបញ្ជីឈ្មោះបោះឆ្នោត៖** ការសិក្សាដោយផ្អែកលើលក្ខខណ្ឌចំនួន ៤ គឺ ១) លេខសម្គាល់នៃការបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត (អ.ខ ឬឯ.អ) ២) ព័ត៌មានពីអំពី ភេទ ៣) គឺព័ត៌មានពីថ្ងៃខែឆ្នាំកំណើត និង ៤) គឺនាមត្រកូល និងនាមខ្លួន ជាលទ្ធផល បានបង្ហាញថា ឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតចំនួន ៩,៧១០,៦៤៥ ឈ្មោះ មានឈ្មោះដូចគ្នា/ស្ទួន ក្នុងបញ្ជីមានចំនួន ៣៦ឈ្មោះ ។ ចំនួនឈ្មោះស្ទួននេះ បើគិតពីអ្នកមានសិទ្ធិបោះឆ្នោត មានចំនួន ១៨នាក់ក្នុងនោះ ឈ្មោះចំនួន ១០ឈ្មោះ មានលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរខុសប្រភេទគ្នា ក្រៅពីនោះ ជាឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទទី៣ ឬថ្មី ។ ក្នុងចំណោមឈ្មោះដូចគ្នា/ស្ទួនចំនួន ១៨នាក់ (ឬ ៣៦ឈ្មោះ) ក្នុងបញ្ជី មានឈ្មោះខ្លះមានស្ទួនក្នុងការិយាល័យតែមួយ ខ្លះមានស្ទួនក្នុងឃុំតែមួយតែខុសការិយាល័យ ខ្លះទៀតស្ទួនក្នុងខេត្តតែខុសតែឃុំសង្កាត់ និងខ្លះទៀតស្ទួនខុសខេត្តគ្នាតែម្តង។

**ឈ្មោះដូចគ្នា/ស្ទួនធៀបមួយលក្ខខណ្ឌ** ៖ បើគិតត្រឹមមួយលក្ខខណ្ឌ គឺលេខឯកសារបញ្ជាក់អត្តសញ្ញាណ (អ.ខ ឬ ឯ.អ) ក្នុងបញ្ជីឈ្មោះបោះឆ្នោតបឋមឆ្នាំ២០២២ មានលេខស្ទួនគ្នាចំនួន ១៦,៣៦៩លេខសម្គាល់ ក្នុងនោះមានចំនួន ១៥,៦៩៦លេខសម្គាល់ ជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ។

**ឈ្មោះដូចគ្នា/ស្ទួន ធៀបឈ្មោះ** ៖ បើគិតត្រឹមមួយលក្ខខណ្ឌ គឺឈ្មោះអ្នកបោះឆ្នោត (នាមត្រកូល និងនាមខ្លួន) ក្នុងបញ្ជីឈ្មោះបោះឆ្នោតបឋមឆ្នាំ២០២២ មានឈ្មោះស្ទួនគ្នាចំនួន ២៩,៣៥៨ឈ្មោះស្មើនឹង ១៤,៦៧៩នាក់។ ករណីនេះ ខុមហ្វ្រែល បានជ្រើសរើសឈ្មោះចំនួន ៥ឈ្មោះមកសិក្សា លទ្ធផលបានបង្ហាញថា ៤ ឈ្មោះ មានចំណុចសម្គាល់ឃើញថា ១) នាមត្រកូល និងនាមខ្លួនដូចគ្នា ២) ភេទ ដូចគ្នា ៣) ថ្ងៃខែឆ្នាំកំណើតដូចគ្នា ៤) រស់នៅក្នុងភូមិដូចគ្នា ៥) តែខុសលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង ៦) រូបថតប្រហាក់ប្រហែល (រូបថតមុន ឬក្រោយចាំបាច់ត្រូវបញ្ជាក់នៅមូលដ្ឋាន) ។ និងមួយឈ្មោះទៀត មានចំណុចសម្គាល់សង្កេតឃើញថា គ្រប់ព័ត៌មានដូចគ្នាទាំងអស់ ខុសគ្នាតែលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

**ការប្រើប្រាស់ឯកសារសម្រាប់ចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត៖** ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៩,៧១០,៦៤៥ឈ្មោះ មានអ្នកប្រើប្រាស់ឯកសារ អ.ខ ប្រភេទទី១ ចំនួន ៤០៥,៧៧៤ឈ្មោះស្មើនឹង ៤.២ភាគរយ អ.ខ ប្រភេទទី២ ចំនួន ២៤៤,៤០០ឈ្មោះស្មើនឹង ២.៥ភាគរយ អ.ខ ប្រភេទទី៣ ចំនួន ៨,២៦៨,៦៨១ឈ្មោះស្មើនឹង ៨៥.២ភាគរយ ឯកសារ អ.ខ ប្រភេទថ្មី ចំនួន ២៩៦,៣៤៨ឈ្មោះ ស្មើនឹង ៣.១ភាគរយ និងឯកសារ ឯ.អ សរុបចំនួន ៤៩៥,៤៤២ឈ្មោះ ស្មើនឹង ៥.១ភាគរយ ។ ឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រភេទទី១ ទី២ និង ឯ.អ ទាំងបីប្រភេទនេះ មានចំនួនសរុប ១,១៤៥,៦១៦ឈ្មោះ ស្មើនឹង ១១.៨ភាគរយនៃឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២២ ត្រូវការចាំបាច់ធ្វើបច្ចុប្បន្នភាពព័ត៌មានឡើងវិញ ដើម្បីឱ្យស្រប

លក្ខខណ្ឌទាំងឡាយទាក់ទងបញ្ជីឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។ ករណីឯកសារ ១១.៨ភាគរយនេះ ខុមហ្វ្រែល សង្កេតឃើញថា ក្រសួងមហាផ្ទៃបានបង្កើនការធ្វើឯកសារនេះយ៉ាងសកម្មនៅតាមមូលដ្ឋាន តែយ៉ាងណា សកម្មភាពទាំងនេះ បានអនុវត្តសកម្មក្រោយការចុះឈ្មោះបោះឆ្នោតដែលមិនអាចធ្វើឱ្យឯកសារទាំងឡាយរបស់អ្នកបោះឆ្នោតមានការផ្លាស់ប្តូរច្រើនក្នុងការប្រើប្រាស់ធ្វើបច្ចុប្បន្នភាពក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២២ ឬប្រើប្រាស់សម្រាប់ការបោះឆ្នោតឆ្នាំ២០២៣ ខាងមុខនោះទេ ។

## ៤. អនុសាសន៍សម្រាប់កែលម្អ

យោងតាមរបាយការណ៍សង្ខេប បានពីការសង្កេត និងការរកឃើញក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែល សូមជូននូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

- គ.ជ.ប គួរតែពង្រឹងបន្ថែមទៀតនូវការផ្សាយព័ត៌មានដល់ក្រុមងាយរងគ្រោះ ជាពិសេសជនពិការ និងការរៀបចំឯកសារឱ្យបានងាយស្រួលសម្រាប់ពួកគេទៅពិនិត្យ ។
- គ.ជ.ប ត្រូវរកវិធីសាស្ត្រក្នុងការផ្តល់ព័ត៌មានទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ពីដំណើរការចុះឈ្មោះរួមទាំងសិក្សារកឱ្យឃើញពីភាគីសំខាន់ក្នុងការផ្តល់ព័ត៌មាន និងនីតិវិធីចែងពីអ្នកទទួលខុសត្រូវនោះ ដើម្បីឱ្យមានភាពប្រាកដថា ប្រជាពលរដ្ឋមានអាយុគ្រប់ចុះឈ្មោះបោះឆ្នោតបានទទួលព័ត៌មាន។
- គ.ជ.ប គួរតែពិនិត្យលទ្ធភាព និងស្រង់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីដែលប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាព ដោយរកវិធីណែនាំពួកគេមុនពេលចុះឈ្មោះបោះឆ្នោត ឱ្យមកធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងបញ្ជីក្នុងពេលចុះឈ្មោះបោះឆ្នោត ។
- គ.ជ.ប គួរតែបន្ថែមការពិនិត្យមើលលើឈ្មោះដូចគ្នា/ស្ទួន ដែលខុមហ្វ្រែលបានផ្តល់ជូន ទាំងឈ្មោះស្ទួនដែលមានព័ត៌មានដូចគ្នា (៣៦ឈ្មោះ) និងឈ្មោះដូចករណីសិក្សា ៥ឈ្មោះ ចេញពីបញ្ជីដែលមានឈ្មោះ (នាមត្រកូល និងនាមខ្លួន) អ្នកបោះឆ្នោត ដូចគ្នា ចំនួនជាង ២ម៉ឺនឈ្មោះ ដែលខុមហ្វ្រែលបានផ្តល់ជូន ។
- គ.ជ.ប គួរតែសហការជាមួយក្រសួងមហាផ្ទៃ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំធ្វើឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងផ្តល់ឱ្យប្រជាពលរដ្ឋឱ្យបានមុនដំណើរការចុះឈ្មោះមកដល់ ។
- គ.ជ.ប គួរតែបន្តជជែកជាមួយតំណាងរាស្ត្រ ឬរដ្ឋសភាជាតិ ឬរដ្ឋាភិបាលពីបញ្ហារាំងស្ទះក្នុងដំណើរការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋចំណាកស្រុកនៅក្រៅប្រទេស និងដើម្បីធានាសិទ្ធិរបស់ពួកគេដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក៏ដូចជាការពង្រឹងសមត្ថភាពនៃការចុះឈ្មោះជូនប្រជាពលរដ្ឋដែលជាតួនាទីរបស់ស្ថាប័ន គ.ជ.ប ផងដែរ។
- គ.ជ.ប គួរតែពិនិត្យមើលនីតិវិធីចំពោះភាគីពាក់ព័ន្ធទាំងឡាយណា ដែលធ្វើសកម្មភាពនាំឱ្យមានការភ័ន្តច្រឡំក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ដូចករណីភាគីមិនមែនជាក្រុមចុះឈ្មោះបោះឆ្នោតស្រង់ឈ្មោះប្រជាពលរដ្ឋពេលមកចុះឈ្មោះ ។


### សម្រាប់ព័ត៌មានបន្ថែម៖

- លោក **គឹម ឈន** នាយកប្រតិបត្តិ ០១២ ៩៤២ ០១៩
- លោក **ភន សាធារឿ** អ្នកសម្របសម្រួលកម្មវិធីអង្កេត និងតស៊ូមតិ ០១១ ៨៨៤ ៨៤០